





ប្រភព : *Encyclopaedia Universalis Version 10*

អត្ថបទ : សំអោ អង្គារតន៍

## ហ្វ្រង់កូហ្វូនី FRANCOPHONIE

ដូចជារៀងរាល់ឆ្នាំដែរ នៅឆ្នាំ ២០០៨នេះ វិទ្យាស្ថានជាតិអប់រំ ក្រោមកិច្ចឧបត្ថមរបស់ទីភ្នាក់ងារឧត្តមសិក្សានៃក្រុម ប្រទេសនិយាយភាសាបារាំង និងក្រោមកិច្ចខិតខំប្រឹងប្រែងរបស់គ្រូវឧទ្ទេស និងលោកគ្រូអ្នកគ្រូទទួលបន្ទុកថ្នាក់នៅវិទ្យាល័យអនុវត្ត វិទ្យាល័យហ៊ុន សែន ប៊ុនរ៉ានីផ្សារដើមថ្កូវ យើងបានរៀបចំពិធីបុណ្យនៃក្រុមអ្នកនិយមភាសាបារាំងនៅក្នុងវិទ្យាស្ថានជាតិអប់រំ។ នៅក្នុងអត្ថបទនេះ យើងខ្ញុំសូមលើកយកប្រវត្តិនៃពិធីបុណ្យមួយនេះ មកបង្ហាញជូនលោកអ្នកទុកគ្រាន់ជាចំណេះដឹងទូទៅដែលអាចផ្សព្វផ្សាយទៅដល់សិស្សានុសិស្ស។



ពាក្យថា Francophonie ដែលយើងបានបកស្រាយជាភាសាខ្មែរថា ការនិយមភាសាបារាំងនោះ ឬដែលអាចពន្យល់តាមជាភាសាបារាំងនៅក្នុងវចនានុក្រម :

*1. Ensemble constitué par les populations francophones (France, Belgique, Canada [Québec, Nouveau-Brunswick, Ontario], Louisiane, Suisse, Afrique, Madagascar, Antilles, Proche-Orient...). La francophonie dans le monde.*

*2. Mouvement en faveur de la langue française. Grand prix de la francophonie.*

ដែលយើងខ្ញុំសូមបកប្រែក្រៅផ្លូវការដែលមានន័យដូច្នេះថា:

ន័យទី ១ : ការរួបរួមគ្នាមួយដែលកើតឡើងដោយប្រជាជាតិដែលនិយាយភាសាបារាំងជាភាសាទី ១ ឬទី២ យ៉ាងហោច ណាស់នៅក្នុងស្ថានភាពទំនាក់ទំនងមួយចំនួនណានោះ ដូចជាប្រទេសបារាំង ប្រទេសបែលហ្ស៊ិក ប្រទេសកាណាដា ៎ ក្រុងកេបិច ៎ ក្រុងប្រាងស្វិកថ្មី

ក្រុងអុងតារីយ៉ូខ ប្រទេសល្វីស៊ីយ៉ាន ប្រទេសស្វីស ទ្វីបអាហ្វ្រិក កោះម៉ាដាហ្គាស្កា កោះអង់ទីយ ប្រទេសនៅមជ្ឈឹមបូព៌ាជាដើម។ ដែលគេឱ្យឈ្មោះថា ប្រទេសនិយមភាសាបារាំងនៅក្នុងពិភពលោក។

ន័យទី ២: ចលនាមួយសម្រាប់ភាសាបារាំង។ ឧទាហរណ៍: ពានរង្វាន់នៃចលនាសម្រាប់ភាសាបារាំង។

ក្រៅពីនិយមន័យដែលគេអាចរកបាននៅក្នុងវចនានុក្រមនានា ដែលយើងអាចធ្វើសំយោគមកថា : គឺជាក្រុមមនុស្សដែលប្រើប្រាស់ភាសាបារាំងយ៉ាងទៀងទាត់ ជាភាសាកំណើត ជាភាសាប្រើប្រាស់ ជាភាសាបង្រៀន ឬជាភាសាដែលខ្លួនជ្រើសរើសក៏ព្រោះថាខ្លួនពេញចិត្តនឹងភាសាមួយនេះ ជាដើមនោះ ពាក្យថា Francophonie នៅតែជាសញ្ញាណមួយដែលមានការលំបាកនៅឡើយសម្រាប់ក្តោបន័យរបស់រួមវា។ មានព្រឹត្តិការជាច្រើនដែលធ្វើឡើងដើម្បីរំលឹកទៅដល់ពាក្យនេះនៅឆ្នាំ ២០០៦ ដែលបង្ហាញច្បាស់អំពីអត្ថន័យដ៏ស៊ីជម្រៅយ៉ាងច្រើនរបស់វា។ អត្ថន័យនៅក្នុងផ្នែកវប្បធម៌ ពិធីបុណ្យ Francophonie នៅប្រទេសបារាំងត្រូវបានពង្រីកខ្លួនរបស់វា ដោយការប្រារព្ធពិធីបុណ្យមួយនេះត្រូវបានគេធ្វើឡើងចាប់ពីខែ មិនារហូតដល់ខែតុលា ដែលក្នុងពិធីបុណ្យនោះគេអាចទស្សនាការតាំងពិពណ៌ទស្សនីយភាពផ្សេងៗ ការប្រគុំតន្ត្រី វេទិកាផ្លាស់ប្តូរបទពិសោធន៍រវាងអ្នកឯកទេស និងអ្នកឯកទេសដែលវេទិកានេះមានការជំរុញឱ្យមានការបោះពុម្ពជាស្នាដៃផ្សេងៗជាដើម។ ឧទាហរណ៍: ដូចជាការផ្សព្វផ្សាយពីស្នាដៃអក្សរសិល្ប៍របស់អ្នកនិពន្ធនិយមភាសាបារាំង។ ចំណែកឯខាងផ្នែកនយោបាយឯណោះវិញ ជំរើសប្រទេសប្លុកខាងកើតបានស្តែងចេញមកដោយការជ្រើសយកទីក្រុងប៊ុយហ្គារេសប្រទេសប៊ុលហ្គារីសម្រាប់ធ្វើជាសន្និសិទ្ធកំពូលនៃអ្នកដឹកនាំរបស់ក្រុមប្រទេសដែលមានភាសាបារាំងជាភាសាជាភាសាយាន ការពង្រីកនៃបណ្តាញអ្នកនិយាយភាសាបារាំង ហើយក៏ប្រហែលជាការផ្លាស់ប្តូរទិសដៅថ្មីនៃផ្នែកការទូតនៃអ្នកនិយមភាសាបារាំងផងដោយផ្តោតគោលដៅទៅលើប្រទេសក្នុងប្លុកអតីតប្រទេសកុម្មុយនីសផងក៏មិនដឹង។

យើងបានដឹងរួចមកហើយថាពាក្យ "Francophonie" ត្រូវបានបង្កើតឡើងលើកតំបូងនៅក្នុងឆ្នាំ ១៨៨០ ដោយអ្នកភូមិសាស្ត្រឈ្មោះ "Onésime Reclus" ដែលបានសង្កេតឃើញពីការរីករាលដាលនៃភាសាបារាំងនៅក្នុងពិភពលោក។ ស្របគ្នាជាមួយនឹងការរីករាលដាលនៃអាណានិគមបារាំងនៅខណៈដែលរបបអាណានិគមបានដកចេញវិញនោះ ពាក្យនេះក៏ត្រូវបានប្រើប្រាស់ឡើងវិញនៅក្នុងន័យផ្សេងមួយទៀត ដែលមានប្រមុខរដ្ឋនៃបណ្តាប្រទេសនៅទ្វីបអាហ្វ្រិកមួយចំនួនបានស្នើឡើង នៅក្នុងនោះក៏មានលោក "Léopold Sédar Senghor និង Habib Bourguiba" ដែលនៅពេលនោះពួកគាត់បានស្នើសុំឱ្យប្រទេសដែលនិយាយភាសាបារាំងរួបរួមគ្នានៅក្នុងក្របខ័ណ្ឌនៃអង្គការអន្តររដ្ឋាភិបាលមួយថ្មីវិញ។ គឺរហូតមកទល់នឹងឆ្នាំ ១៩៧០ នៅក្នុងសន្និបាតនៅ Niamey អង្គភាពទីមួយនៃកិច្ចសហប្រតិបត្តការពហុភាគីរវាងប្រទេសនិយមភាសាបារាំងត្រូវបានបង្កើតឡើងដោយប្រសិទ្ធិនាមថា ទីភ្នាក់ងារកិច្ចសហប្រតិបត្តការវប្បធម៌ និងបច្ចេកទេស (A.C.C.T: Agence de cooperation culturelle et technique)។ ចុងក្រោយ កាលពីឆ្នាំ ១៩៨៦ នៅក្នុងសន្និសិទកំពូលលើកទី១នៃប្រមុខរដ្ឋាភិបាល និងរដ្ឋាភិបាលនៃប្រទេសនានាដែលមានការប្រើប្រាស់ភាសាបារាំងដូចគ្នា ក៏មានការបង្កើតចេញជារូបរាងច្បាស់លាស់មួយនៃហ្វ្រង់កូហ្វូនីជាលក្ខណៈស្ថាប័ន។ កិច្ចប្រជុំកំពូលផ្សេងៗជាបន្តបន្ទាប់មកទៀតត្រូវបានធ្វើឡើងនៅទីក្រុងនានាដូចជានៅឆ្នាំ ១៩៨៧ នៅកេបិចប្រទេសកាណាដា ឆ្នាំ ១៩៨៩នៅទីក្រុងដាកាប្រទេសសេណេហ្គាល់ នៅឆ្នាំ ១៩៩១ នៅវាជវាំងសាយ៉ូប្រទេសបារាំង នៅឆ្នាំ ១៩៩៣នៅកោះម៉ូរីសនៅឆ្នាំ ១៩៩៥នៅទីក្រុងបូតូនូប្រទេសបេណាំង នៅឆ្នាំ ១៩៩៧ នៅទីក្រុងហាណូយប្រទេសវៀតណាម នៅឆ្នាំ ១៩៩៩នៅទីក្រុងម៉ុងតុងប្រទេសកាណាដា នៅឆ្នាំ ២០០២នៅទីក្រុងបីរូតប្រទេសលីបង់ នៅឆ្នាំ ២០០៤នៅទីក្រុងអូអាហ្គាឌូហ្គូប្រទេសបួរគីណា និងនៅឆ្នាំ ២០០៦ នៅទីក្រុងប៊ុយហ្គារេសប្រទេសប៊ុលហ្គារី ដែលប្រការនេះគឺជាសក្ខីភាពបង្ហាញពីការរីកធំឡើងនៃចំនួនប្រទេសដែលបានចូលរួមនៅក្នុងសន្និសិទនេះ។



ទីភ្នាក់ងារកិច្ចសហប្រតិបត្តការវប្បធម៌ និងបច្ចេកទេស (A.C.C.T)

បានក្លាយទៅជាទីភ្នាក់ងារហ្វ្រង់កូហ្វូនីនៅឆ្នាំ ១៩៩៥ ហើយក៏បានប្រែឈ្មោះម្តងទៀតទៅជាអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (O.I.F: Organisation international de la francophonie)។ រហូតមកទល់សព្វថ្ងៃ អង្គការមួយនេះរួមមានរដ្ឋនិងរដ្ឋាភិបាលចំនួន ៥៣ជាសមាជិកពេញសិទ្ធិ រដ្ឋនិងរដ្ឋាភិបាល២ ជាសមាជិកបម្រុង និង រដ្ឋនិង រដ្ឋាភិបាល ១៣ ជាអ្នកសង្កេតការ។ ការដាក់ប្រទេសហ្កាណាជាសមាជិកបម្រុង ប្រទេសម៉ូសំប៊ិក និងប្រទេសអ៊ុយក្រែនជាប្រទេសសង្កេតការជាសក្ខីកម្មនៃកំណើនដ៏ខ្លាំងរបស់ក្រុមប្រទេសនិយមភាសាបារាំង ដែលនេះជាការបញ្ជាក់ឱ្យឃើញថាប្រទេសនិយមភាសាបារាំងបានរីករាលដាលឆ្លងផុតពីព្រំដែននៃភូមិសាស្ត្រភាសានៃភាសាបារាំងទៅទៀត។ ក្នុងន័យនេះ យើងអាចនិយាយបានថាបណ្តាប្រទេសដែលមិនមែនជាសមាជិកនៃក្រុមប្រទេសអ្នកនិយមភាសាបារាំងនោះ មិនមែនមិនមានអ្នកប្រើប្រាស់ភាសាបារាំងឬចេះនិយាយភាសាបារាំងនោះទេ ឧទាហរណ៍ដូចជាប្រទេសកូរ៉េខាងត្បូងដែលប្រទេសនេះមិនមានលក្ខន្តិកៈអ្វីមួយឡើយនៅក្នុងក្រុមប្រទេសអ្នកនិយមភាសាបារាំង តែផ្ទុយទៅវិញចំនួនអ្នកនិយមភាសាបារាំងគិតជាភាគរយមានចំនួនច្រើនជាងប្រទេសខ្លះដែលជាសមាជិករបស់ប្រទេសនិយមភាសាបារាំងទៅទៀត (ទិន្នន័យដែលផ្តល់ដោយលោក Louis Arsac អនុព័ន្ធកិច្ចសហប្រតិបត្តការបារាំងប្រចាំស្ថានទូតបារាំងនៅកម្ពុជា ក្នុងឱកាសនៃវេទិកាសាធារណៈស្តីពីការងារសម្រាប់អ្នកនិយមភាសាបារាំងនៅកម្ពុជា)។ នៅក្នុងន័យនេះ ចំណេះដឹងខាងភាសាបរទេសរបស់ ប្រជាពលរដ្ឋនៅក្នុងប្រទេសមួយស្តែងចេញពីភាពរឹងមាំនៅក្នុងវិស័យសិក្សាធិការរបស់ប្រទេសមួយនោះ មានន័យថាកាលណាប្រព័ន្ធអប់រំកាន់តែរឹងមាំនោះចំណង់ចំណូលចិត្តក្នុងការសិក្សាភាសាបរទេសរបស់ប្រជាជាតិមួយនឹងកើនឡើងដោយខ្លួនឯងជាក់ជាមិនខាន។ ការសិក្សាភាសាបរទេសមួយគឺមិនសំដៅទៅលើការដែលភាសាមួយនោះជាទំនោរជាទូទៅនៅក្នុងសង្គមមួយនោះទេ តែវាគឺជាទិសដៅរបស់អ្នកសិក្សាដោយខ្លួនឯងឯណោះទៅវិញ។ ដូចដែលពាក្យមួយឃ្លាដែលគេ លើកឡើងថា "Une langue de plus, une chance de plus"។

## ភូមិវិទ្យានៃហ្វ្រង់កូហ្វូនី

តថភាពរបស់ហ្វ្រង់កូហ្វូនីជាចលករមួយដ៏រស់រវើក។ នៅក្នុងប្រទេសមួយចំនួនដែលល្បីល្បាញថាជាប្រទេសនិយមភាសាបារាំង ភាសាបារាំងគឺជាភាសាតាមកាលៈទេសៈ មានន័យថាជាភាសាមួយដែលគេប្រើប្រាស់វានៅក្នុងស្ថានភាពទំនាក់ទំនងពិសេសនានាណាមួយ រួចបន្ទាប់មកគេលែងប្រើប្រាស់វាដោយត្រឡប់មកប្រើប្រាស់ភាសាកំណើត ឬក៏ត្រឡប់ទៅប្រើប្រាស់ភាសាណាមួយផ្សេងទៀតវិញ។ សូម្បីតែនៅប្រទេសបារាំងក៏ដោយក៏ប្រហែលជាវាជាការស្រមើ ស្រមៃមួយដែលប្រសិនណាជាគេគិតថាជាប្រទេសដែលមានឯកភាពភាសានោះ។ ទោះបីជាមាននយោបាយស្តីពីភាសាដែលត្រូវឯកភាពដែលធ្លាប់អនុវត្តកន្លងមកតាំងពីរាប់សតវត្សមកដោយយកភាសាបារាំងដែលប្រើប្រាស់ដោយអ្នករស់នៅទីក្រុងប៉ារីសជាភាសាគោលក៏ដោយ ក៏ការរស់រានមានជីវិតនៃបណ្តារលក្ខណៈពិសេសនានារបស់ភាសាមួយ នេះនៅតាមតំបន់ផ្សេងៗ និងការប៉ុនប៉ងក្នុងការបង្កើតឡើងវិញនៃភាសាតាមតំបន់ស្តែងចេញឱ្យឃើញនូវការតស៊ូ របស់ស្ថានភាពនានានៃនិន្នាការទៅរកពហុភាសារបស់ប្រជាពលរដ្ឋបារាំង។ ដោយហេតុនេះហើយទើបបានជានៅក្នុងប្រទេសបារាំងមានការជំរុញឱ្យរក្សាទុកនូវភាសាតំបន់របស់ខ្លួន ដែលប្រការនេះក៏គឺជាការការពារនូវវប្បធម៌ អរិយធម៌របស់ក្រុម របស់កុលសម្ព័ន របស់ប្រទេស របស់មនុស្សជាតិទាំងមូលផងដែរ។

នៅក្នុងហ្វ្រង់កូហ្វូនី គេអាចចែកចេញជាស្ថានភាពភូមិសាស្ត្រភាសាជាបួនប្រភេទធំៗគឺ: ប្រទេសនិយាយភាសាបារាំងជាភាសាកំណើត (នៅទ្វីបអឺរ៉ុបនិងនៅប្រទេសកាណាដា) ប្រទេសនិយាយភាសាអាណានិគមដែលភាសាបារាំងនៅក្នុងប្រទេសទាំងនោះគឺជាភាសាផ្លូវការ ឬក៏ជាភាសាប្រើប្រាស់ប្រចាំថ្ងៃដោយប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេសទាំងនោះ ដែលមានភាសាអាណានិគមជាភាសាកំណើត (នៅកោះអង់ទីយប្រទេស ហៃទី ប្រទេសហ្គុយយ៉ាន កោះម៉ូរីស កោះសីសែល) ប្រទេសដែលភាសាបារាំងត្រូវបានប្រើប្រាស់ជាភាសាសម្រាប់ទំនាក់ទំនងប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមួយភាគ ហើយដែលច្រើនតែប្រើប្រាស់ភាសានេះជាភាសាផ្លូវការ (គឺជាប្រទេសដែលធ្លាប់ត្រូវបានធ្វើអាណានិគម ឬត្រួតត្រាដោយប្រទេសបារាំងមានដូចជា ប្រទេសអាហ្វ្រិកស្បែកខ្មៅ ប្រទេសម៉ាដាហ្គាស្កា ក្រុមប្រទេសម៉ាហ្រ្គេប ប្រទេសលីបង់ កោះមួយចំនួននៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកជាដើម) និងទីបួននោះ គឺពពួកកោះហ្វ្រង់កូហ្វូន ដែលនៅទីនោះភាសាបារាំងត្រូវបានប្រើប្រាស់ដោយក្រុមមនុស្សមួយចំនួន ឬក៏ក្នុងស្ថានភាពច្បាស់លាស់ណាមួយដែលស្ថិតក្នុងស្ថានភាពនេះ ភាសាបារាំងរក្សាបាននូវតួនាទីមួយចំនួនណានោះរបស់ខ្លួន (មជ្ឈឹមបូព៌ា អឺរ៉ុបខាងកើត ជ្រោយឥណ្ឌូចិន ជាដើម)។

ឯកសារយោង :

- *Encyclopédie Universallie 2008*
- *Le Petit Robert format numérique de 2001*
- *Émission : Apsara TV du Cambodge*
- *Carte des pays francophones*

អត្ថបទ : សំអោ អង្គារតន៍